# ក

# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៦-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤០៥ ស្តីពីការតែងតាំងឯកឧត្តម អ៊ុង គឹមអន បច្ចុប្បន្ន ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង អ៊ីតាលី អេស្ប៉ាញ ព័រទុយហ្គាល់ ក្រិច និង បូរីក្សត្រអង់ដ័រ អោយទទួលភារកិច្ចបន្ថែមជា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំប្រទេសម៉ាល់តា និងស៊ីប្រ ដោយមាននិវេសនដ្ឋាន នៅទីក្រុងប៉ារីស ២៧១៧

០៦-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤០៦ ស្តីពីការតែងតាំងឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ២៧១៨

០៧-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤០៨ ស្តីពីការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ ចំពោះសព ឯកឧត្តម តែប ថន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ២៧១៩

០៧-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤០៩ ស្តីពីការប្រោសព្រះរាជទាន ចំពោះ អស់លោក ជាជនបរទេស ចំនួន ០៥ រូប នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ២៧២០

០៧-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤១០ ស្តីពីការប្រោសព្រះរាជទាន ចំពោះ នាយទាហាន ជាន់ខ្ពស់ ចំនួន ០២ រូប នូវគ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ ២៧២១

០៧-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤១១ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ការពារជាតិ តាមលំដាប់ថ្នាក់ ចំពោះ អង្គភាព ចំនួន ៧៩ ២៧២២

០៧-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤១២ ស្តីពីការប្រោសព្រះរាជទាន ប្រគេនចំពោះ ព្រះតេជគុណ គឹម សំបូរ នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ២៧២៤

០៧-៤-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៤០៩/៤១៣ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា ២៧២៥

១០-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤១៩ ស្តីពីការតែងតាំងឯកឧត្តម ង៉ាន់ ស៊ឿន ជា ឧកញ៉ា ២៧៣៤

១០-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤២០ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម,ឧកញ៉ា,លោកជំទាវ និងអស់លោក ចំនួន ១៣ រូប ២៧៣៥

១០-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤២១ ស្តីពីការប្រោសព្រះរាជទាន ចំពោះ លោកជំទាវ ស៊ាងលីម លីហួរ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ២៧៣៦

១០-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤២២ ស្តីពីការតែងតាំងលោក **អ៊ាត ម៉ុនថុល** និងលោក **អ៊ាត សីម៉ា** ជា ឧកញ៉ា ២៧៣៧

១០-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤២៣ ស្តីពីការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម **ឆាយ ថន** នូវគ្រឿងឥស្សរិយយស ជាតួបការ ២៧៣៨

១០-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤២៤ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងលោកជំទាវ ចំនួន ២២ រូប ២៧៣៩

១០-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤២៥ ស្តីពីការតែងតាំងឯកឧត្តម **ហែម មូ** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ២៧៤០


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


២០-៤-២០០៩ -អនុក្រឹត្យលេខ ៥៨ អនក្រ.បក ស្តីពីការបិទស្ថានប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការយូណេស្កូ នៅទីក្រុងប៉ារីស ២៧៤១

២០-៤-២០០៩ -អនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២៧៤២

២០-៤-២០០៩ -អនុក្រឹត្យលេខ ៦០ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ ២៧៤៤

០៨-៤-២០០៩ -អនុក្រឹត្យលេខ ៥៤០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៧៤៩

០៨-៤-២០០៩ -អនុក្រឹត្យលេខ ៥៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៥១

០៨-៤-២០០៩ -អនុក្រឹត្យលេខ ៥៤២ អនក្រ.តត ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ២៧៥២

០៨-៤-២០០៩ - អនុក្រឹត្យលេខ ៥៤៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយនគរបាលជាតិ ២៧៥៣

០៨-៤-២០០៩ -អនុក្រឹត្យលេខ ៥៤៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧៥៥

០៨-៤-២០០៩ -អនុក្រឹត្យលេខ ៥៤៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧៥៦

០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៤៦ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៧៥៧

០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៤៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៥៨

០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៤៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧៥៩

០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៦១

០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៥០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៧៦២

០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៥១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៦៣

០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៥២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៧៦៤
០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៥៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៧៦៥
០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៥៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៦៦
០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៥៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៧៦៨
០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៥៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៦៩
០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៥៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៧៧០
០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៥៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៧៧៣
០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៧៤
០៩-៤-២០០៩ -អនុក្រឹត្យលេខ ៥៦០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៧៦
២០-៤-២០០៩ -អនុក្រឹត្យលេខ ៥៦១ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ២៧៧៧
២០-៤-២០០៩ -អនុក្រឹត្យលេខ ៥៦២ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៧៧៨
២០-៤-២០០៩ -អនុក្រឹត្យលេខ ៥៦៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ២៧៧៩

## ២~សេចក្តីសំរេច

២០-៤-២០០៩ -សេចក្តីសំរេចលេខ ២៦ សសរ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការពានរង្វាន់យុវជនដែលមានភាពជាអ្នកដឹកនាំប្រចាំឆ្នាំ ២៧៨០

## III~ការងារបណ្តាក្រសួង

## ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

១៨-០២-២០០៩ -ប្រកាសលេខ ១១៣ ប្រក.សកដជ ស្តីពីការប្រឡងយកវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពរបស់គ្រូបង្ហាត់បើកបរយានយន្ត និងគណៈកម្មការប្រឡងយកប័ណ្ណបើកបរ នៅរាជធានី ខេត្ត ២៧៨២

## ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៤៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមប្រ៊ីជ ឆាលដ៍ ឌីវេឡុបមេន សេនធ័រ** ២៧៨៦
០១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៥២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន និងសាខាក្រុមហ៊ុន **ហ័ង ហ្វា ហ្វាត ធេលីខម ឌីវេឡុបមេន ខនស្រ្តាក់សិន ខមភេនី លីមីធីត** ២៧៨៨
០១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៥៣ ពណ.ចបព ស្តីពីការអនុញ្ញាតជាគោលការណ៍អោយបង្កើតការិយាល័យតំណាងពាណិជ្ជកម្ម នៃក្រុមហ៊ុន **អូឌិន យ៉ញ ស្តុត ខមភេនី " ប៉ូរីយ៉ាហ្គេសស្ត្រូយ "** ដែលមានទីស្នាក់ការ តាំងនៅសង្កាត់ផ្សារថ្មីទី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ២៧៨៩

០២-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៦២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម ភី ឌី** ២៧៩០

០២-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៦៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស ស៊ី អិម ខមភេនី លីមីធីត** ២៧៩២

០២-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៦៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វមូឡា លីស ធេលីខម & ខនស្ត្រាក់សិន** ២៧៩៤

០២-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៦៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អោ ម៉ាយ អិន ស៊ី ថេលីខមម្មូនីខេសិន (ខេមបូឌា)** ២៧៩៦

០២-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៦៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីធី មេឌា & ខនស្ត្រាក់សិន ឃ្យូ អិលធីឌី** ២៧៩៨

០២-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៦៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ណានីម៉ា ខបភើរេសិន អិលធីឌី** ២៨០០

០២-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៦៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដុង ជីន ខ្មែរ អិលធីឌី** ២៨០២

០២-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៩៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ អ ឌី គ្រុប** ២៨០៤

០២-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៩៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស ខេ អាយ អេស (ខេមបូឌា) តេទ្រូឡៀម** ២៨០៦

០៣-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៩៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេម ឌី អិន ខេ អេស៊ា** ២៨០៨

០៣-៩-២០០៨ -លិខិតបញ្ជាក់លេខ ៤៨៩៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អូសាកា ខបភើរេសិន** ២៨១០

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤០៥

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ / នស / ៩៤ / ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម អ៊ុជ គឹមអន បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង អ៊ីតាលី អេស្ប៉ាញ ព័រទុយហ្កាល់ ក្រិច និង បូរីក្សត្រអង់ដ័រ អោយទទួលភារកិច្ចបន្ថែមជា ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព ប្រចាំប្រទេស ម៉ាល់តា និងស៊ីប្រ ដោយមាននិវេសនដ្ឋាននៅទីក្រុងប៉ារីស ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៩០៤.៤០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៣៦៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដូចមានរាយនាមខាងក្រោម÷

- ឯកឧត្តម **អ៊ិន សុខុម**
- ឯកឧត្តម **សុខ សារាវណ្ណ**

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

៣៩៧.០៩០៤.៤០៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៣៦៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជាកិច្ចបច្ឆាមរណៈ

ចំពោះសព

ឯកឧត្តម កែប ជុន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៩៧.០៩០៤.៤១១

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ លេខ: ៣៧៥ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ[illegible] ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១-H.E SHIN HYUN-SUK
២-Mr. KIM BYUNG-GWAN
៣-Mr. SON SUNG-IL
៤-Mr. LEE KIL-SOO
៥-Mr. HORT-SROEU

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០៤.៤១២

លេខ: ៣៨៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ មេសា ឆ្នាំ២០០៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១-ឧត្តមសេនីយ៍ទោ ង៉ែត នរិន្ទ្រ

២-ឧត្តមសេនីយ៍ទោ លី កុសល

នូវ

## គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៩៧.០៩០៤.៤១៣

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ លេខ :៣៧៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤១១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

នូវ

### ក-គ្រឿងឥស្សរិយយស មាសការពារជាតិ ចំពោះ :-

១-កងពលតូចអន្តរាគមន៍លេខ ១១ បញ្ជាការដ្ឋានកងទ័ពជើងគោក
២-វរសេនាតូចលេខ ១១១ កងពលតូចអន្តរាគមន៍ លេខ ១១
៣-វរសេនាតូចលេខ ១១២ កងពលតូចអន្តរាគមន៍ លេខ ១១
៤-វរសេនាតូចលេខ ១១៣ កងពលតូចអន្តរាគមន៍ លេខ ១១
៥-វរសេនាតូចលេខ ១១៤ កងពលតូចអន្តរាគមន៍ លេខ ១១
៦-កងពលតូចអន្តរាគមន៍លេខ ១២ បញ្ជាការដ្ឋានកងទ័ពជើងគោក
៧-វរសេនាតូចលេខ ១៤១ កងពលតូចអន្តរាគមន៍លេខ ១៤
៨-វរសេនាតូចស៊ើបការណ៍ យោធភូមិភាគពិសេស
៩-វរសេនាតូចលេខ ១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង
១០-វរសេនាតូចលេខ ១ តំបន់ប្រតិបត្តិការសឹករងកណ្តាល
១១-យោធភូមិភាគទី ៣ បញ្ជាការដ្ឋានកងទ័ពជើងគោក
១២-កងការពារព្រំដែន ៤០១ យោធភូមិភាគទី ៤
១៣-កងការពារព្រំដែន ៤០២ យោធភូមិភាគទី ៤
១៤-កងការពារព្រំដែន ៤០៣ យោធភូមិភាគទី ៤
១៥-កងការពារព្រំដែន ៤០៤ យោធភូមិភាគទី ៤
១៦-កងពលតូចថ្មើរជើង លេខ៤១ យោធភូមិភាគទី ៤
១៧-កងពលតូចថ្មើរជើង លេខ៤២ យោធភូមិភាគទី ៤
១៨-តំបន់ប្រតិបត្តិការសឹករង កំពង់ធំ យោធភូមិភាគទី ៤
១៩-តំបន់ប្រតិបត្តិការសឹករង សៀមរាប យោធភូមិភាគទី៤
២០-តំបន់ប្រតិបត្តិការសឹករង ព្រះវិហារ យោធភូមិភាគទី ៤
២១-តំបន់ប្រតិបត្តិការសឹករង ឧត្តរមានជ័យ យោធភូមិភាគទី៤
២២-វរសេនាតូចវិស្វកម្ម យោធភូមិភាគទី ៤
២៣-វរសេនាតូចស៊ើបការណ៍ យោធភូមិភាគទី ៤
២៤-វរសេនាតូចកាំភ្លើងធំ យោធភូមិភាគទី ៤
២៥-វរសេនាតូចរថក្រោះ យោធភូមិភាគទី ៤
២៦-យោធភូមិភាគទី ៥ បញ្ជាការដ្ឋានកងទ័ពជើងគោក
២៧-កងពលតូចថ្មើរជើងលេខ ៥២ យោធភូមិភាគទី ៥
២៨-តំបន់ប្រតិបត្តិការសឹករងបាត់ដំបង យោធភូមិភាគទី ៥
២៩-កងការពារព្រំដែនគោកលេខ ៥០១ យោធភូមិភាគទី៥
៣០-វរសេនាតូចស៊ើបការណ៍ យោធភូមិភាគទី ៥
៣១-ផ្នែកលេខាធិការដ្ឋាន យោធភូមិភាគទី ៥
៣២-ការិយាល័យ ទី ១ យោធភូមិភាគទី ៥
៣៣-មន្ទីរពេទ្យ យោធភូមិភាគទី ៥

### ខ-គ្រឿងឥស្សរិយយស ប្រាក់ការពារជាតិ ចំពោះ :-

១-ការិយាល័យ ទី១ កងពលតូចអន្តរាគមន៍ លេខ ១១
២-ការិយាល័យ ទី៤ កងពលតូចអន្តរាគមន៍ លេខ ១១
៣-ការិយាល័យ ទី៥ កងពលតូចអន្តរាគមន៍ លេខ ១១
៤-ការិយាល័យហ្វឹកហ្វឺន កងពលតូចអន្តរាគមន៍ លេខ ១១
៥-ផ្នែកលេខាធិការដ្ឋាន កងពលតូចអន្តរាគមន៍ លេខ ១១
៦-កងអនុសេនាធំការពារ កងពលតូចអន្តរាគមន៍ លេខ ១១
៧-កងអនុសេនាធំការពារអាកាស កងពលតូចអន្តរាគមន៍ លេខ ១១
៨-កងអនុសេនាធំដឹកជញ្ជូន កងពលតូចអន្តរាគមន៍ លេខ ១១
៩-កងអនុសេនាធំស៊ើបការណ៍ កងពលតូចអន្តរាគមន៍ លេខ ១១
១០-កងអនុសេនាធំវិស្វកម្ម កងពលតូចអន្តរាគមន៍ លេខ ១១
១១-កងអនុសេនាធំបញ្ជូនសារកងពលតូចអន្តរាគមន៍លេខ ១១
១២-កងអនុសេនាធំកាំភ្លើងធំ កងពលតូចអន្តរាគមន៍លេខ ១១
១៣-គិលានដ្ឋានសុខាភិបាល កងពលតូចអន្តរាគមន៍ លេខ ១១
១៤-វរសេនាតូចលេខ ១២១ កងពលតូចអន្តរាគមន៍ លេខ ១២

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL
ព្រះរាជវាំង

១៥-វរសេនាតូចលេខ ១៤២ កងពលតូចអន្តរាគមន៍ លេខ ១៤
១៦-តំបន់ប្រតិបត្តិការសឹករងកោះកុង យោធភូមិភាគទី ៣
១៧-តំបន់ប្រតិបត្តិការសឹករងកំពត យោធភូមិភាគទី ៣
១៨-តំបន់ប្រតិបត្តិការសឹករងតាកែវ យោធភូមិភាគទី ៣
១៩-កងពលតូចថ្មើរជើងលេខ ៥១ យោធភូមិភាគទី ៥
២០-តំបន់ប្រតិបត្តិការសឹករងពោធិសាត់ យោធភូមិភាគទី ៥
២១-កងការពារព្រំដែនគោក ៥០៤ យោធភូមិភាគទី ៥
២២-វរសេនាតូច វិស្វកម្ម យោធភូមិភាគទី ៥
២៣-ការិយាល័យ ទី៣ យោធភូមិភាគទី ៥
២៤-ការិយាល័យ ហ្វឹកហ្វឺន យោធភូមិភាគទី ៥
២៥-សាលាពលទាហាន ទី៥ យោធភូមិភាគទី ៥

### គ-គ្រឿងឥស្សរិយយស សិរីវឌ្ឍការពារជាតិ ចំពោះ :-

១-ការិយាល័យ ទី ២ កងពលតូចអន្តរាគមន៍ លេខ ១១
២-ការិយាល័យ ទី ៣ កងពលតូចអន្តរាគមន៍ លេខ ១១
៣-ផ្នែកហិរញ្ញវត្ថុ កងពលតូចអន្តរាគមន៍ លេខ ១១
៤-ការិយាល័យ អភិវឌ្ឍន៍ កងពលតូចអន្តរាគមន៍ លេខ ១១
៥-កងអនុសេនាធំទី៣ វរសេនាតូចលេខ ១១១ កងពលតូចអន្តរាគមន៍ លេខ ១១
៦-កងអនុសេនាធំទី៤ វរសេនាតូចលេខ១១២ កងពលតូច អន្តរាគមន៍ លេខ ១១
៧-កងអនុសេនាធំទី៩ វរសេនាតូចលេខ ១១៣ កងពលតូចអន្តរាគមន៍ លេខ ១១
៨-កងអនុសេនាធំទី១២ វរសេនាតូចលេខ១១៤ កងពលតូចអន្តរាគមន៍ លេខ ១១
៩-វរសេនាតូចលេខ ១២៤ កងពលតូចអន្តរាគមន៍ លេខ ១២
១០-វរសេនាតូចលេខ ១៤៣ កងពលតូចអន្តរាគមន៍ លេខ ១៤
១១-វរសេនាតូចលេខ ១៤៤ កងពលតូចអន្តរាគមន៍ លេខ ១៤
១២-តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ យោធភូមិភាគទី ៣
១៣-តំបន់ប្រតិបត្តិការសឹករងក្រុងកែប យោធភូមិភាគទី ៣
១៤-តំបន់ប្រតិបត្តិការសឹករងកំពង់ស្ពឺ យោធភូមិភាគទី ៣
១៥-កងពលតូចថ្មើរជើង លេខ ៥៣ យោធភូមិភាគទី ៥
១៦-តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ យោធភូមិភាគទី ៥
១៧-កងការពារព្រំដែនគោក លេខ ៥០៣ យោធភូមិភាគទី ៥
១៨-វរសេនាតូចការពារអាកាស យោធភូមិភាគទី ៥
១៩-ការិយាល័យ ទី៤ យោធភូមិភាគទី ៥
២០-ការិយាល័យការពារព្រំដែន យោធភូមិភាគទី ៥
២១-តំបន់អភិវឌ្ឍន៍ យោធភូមិភាគទី ៥

៣៩៧.០៩០៤.៤១៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៣៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤១២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ប្រគេនចំពោះ

ព្រះតេជគុណ គីម សំបូរ

នូវ

គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.០៩០៤.៤១៥

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៣៧៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤២៣

## ស្តីពី

## ការបង្កើតគណៈវិស្វករកម្ពុជា

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ១ ..**

ត្រូវបានបង្កើតគណៈវិស្វករកម្ពុជា ដែលសរសេរកាត់ថា "គ.វិ.ក." ដើម្បីប្រមូលផ្តុំ និងគ្រប់គ្រងវិស្វករចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ ..**

ព្រះរាជក្រឹត្យនេះមានគោលបំណងដូចតទៅ ៖

- រួមចំណែករៀបចំវិជ្ជាជីវៈវិស្វកម្មឱ្យកាន់តែល្អប្រសើរ ដើម្បីការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់វិស្វករ
- រួមចំណែកថែរក្សា និងលើកស្ទួយអត្តសញ្ញាណជាតិ
- ពង្រឹងសមត្ថភាពបច្ចេកទេសគ្រប់ជំនាញ និងពង្រីកធនធានមនុស្សឱ្យស្របតាមកាលៈទេសៈបច្ចុប្បន្ន និងអនាគត
- ធានាឱ្យការប្រកបវិជ្ជាជីវៈវិស្វកម្មមានគុណភាព ប្រសិទ្ធភាព សុវត្ថិភាព ស្ថិរភាព និងការទទួលខុសត្រូវខ្ពស់
- ពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងផ្ទៃក្នុងវិស្វកម្មថ្នាក់ជាតិ និងទំនាក់ទំនងរវាងវិស្វកម្មជាតិ និងវិស្វកម្មអន្តរជាតិ
- ទទួលស្គាល់គុណភាពរបស់វិស្វករកម្ពុជា ដើម្បីឱ្យមានគោរម្យងារជាវិស្វករអាជីពជាតិ និងអន្តរជាតិ
- រួមចំណែកក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈវិស្វកម្ម ដើម្បីអភិវឌ្ឍធនធានមនុស្សឱ្យស្របតាមតម្រូវការសង្គម ។

**មាត្រា ៣ ..**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះវិស្វករខ្មែរ និងវិស្វករបរទេសដែលបានចុះបញ្ជីនៅ គ.វិ.ក. ។ ព្រះរាជក្រឹត្យនេះមិនមានវិសាលភាពអនុវត្តចំពោះវិស្វករ ដែលកំពុងបំពេញការងារក្នុងក្របខណ្ឌក្រសួង និងស្ថាប័នរដ្ឋឡើយ ។

**មាត្រា ៤ ..**

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងព្រះរាជក្រឹត្យនេះមាននិយមន័យដូចតទៅ ៖

- វិស្វករ សំដៅដល់រូបវន្តបុគ្គលខ្មែរ និងបរទេសដែលបានបញ្ចប់ការសិក្សាជំនាញវិស្វកម្មដោយជោគជ័យនៅតាមគ្រឹះស្ថានឧត្តមសិក្សានានានៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ហើយមានការទទួលស្គាល់សញ្ញាបត្រស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា

- វិស្វករអាជីព សំដៅដល់វិស្វករខ្មែរ និងវិស្វករបរទេស ដែលបានចុះឈ្មោះទទួលស្គាល់ក្នុងបញ្ជីនៃ គ.វិ.ក. និងបានបំពេញលក្ខខណ្ឌស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា

- វិស្វករអាស៊ាន សំដៅដល់រូបវន្តបុគ្គលដែលមានសញ្ជាតិ ក្នុងប្រទេសជាសមាជិកអាស៊ាន និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ ស្របតាមកិច្ចព្រមព្រៀងនៃការទទួលស្គាល់គ្នាទៅវិញទៅមកលើសេវាកម្មវិស្វកម្មរបស់អាស៊ាន ក្រោមការត្រួតពិនិត្យ និងវាយតម្លៃរបស់គណៈកម្មាធិការចុះបញ្ជីវិស្វករអាស៊ាន

- វិជ្ជាជីវៈវិស្វកម្ម សំដៅដល់ការងារពាក់ព័ន្ធនឹងការសិក្សាគម្រោង ការអនុវត្ត និងលិខិតបទដ្ឋានបច្ចេកទេសទាំងឡាយ ដែលទាក់ទងនឹងការងារវិស្វកម្ម ។

## ជំពូកទី២
## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈវិស្វករកម្ពុជា
### ផ្នែកទី១
### ប្រធានកិត្តិយសនៃគណៈវិស្វករកម្ពុជា



**មាត្រា ៥ ..**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស នៃ **គ.ទិ.ក.**។

**មាត្រា ៦ ..**

ប្រធានកិត្តិយស នៃ **គ.ទិ.ក.** ជាអធិបតីក្នុងមហាសន្និបាត **គ.ទិ.ក.** និងផ្តល់អនុសាសន៍ដល់ **គ.ទិ.ក.**។

## ផ្នែកទី២

## មហាសន្និបាត

**មាត្រា ៧ ..**

- មហាសន្និបាតប្រចាំឆ្នាំ **គ.ទិ.ក.** ត្រូវប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធាន ក្រុមប្រឹក្សា **គ.ទិ.ក.**

- មហាសន្និបាត **គ.ទិ.ក.** ប្រព្រឹត្តទៅ ០៥(ប្រាំ) ឆ្នាំម្តង ដើម្បីរៀបចំការបោះឆ្នោតជ្រើសរើសអគ្គលេខាធិការ និង អគ្គលេខាធិការរង

- មហាសន្និបាតវិសាមញ្ញអាចប្រព្រឹត្តទៅបាន តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សា **គ.ទិ.ក.** ឬតាមការស្នើសុំពីវិស្វករចុះបញ្ជីយ៉ាងតិចចំនួន៣០ (សាមសិប) ភាគរយ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃប្រជុំ ដោយមានភ្ជាប់របៀបវារៈមកជាមួយផង។

**មាត្រា ៨ ..**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មហាសន្និបាត **គ.ទិ.ក.** ដូចមានចែងក្នុងមាត្រា ៧ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង **គ.ទិ.ក.**។

## ផ្នែកទី៣

## ក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា

**មាត្រា ៩ ..**

ក្រុមប្រឹក្សា **គ.ទិ.ក.** មានសមាសភាពដូចតទៅ÷

| | |
|---|---|
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - ឥស្សរជនជាន់ខ្ពស់នៃស្ថាប័នជាតិដែលមានបទពិសោធខាងវិស័យវិស្វកម្ម | អនុប្រធាន |
| - តំណាងក្រសួងស្ថាប័នដែលពាក់ព័ន្ធនឹងវិស័យវិស្វកម្ម | សមាជិក |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃរាជរដ្ឋាភិបាល | សមាជិក |
| - តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| - តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| - អគ្គលេខាធិការ **គ.ទិ.ក.** | សមាជិកអចិន្ត្រៃយ៍ |

សមាសភាពក្រុមប្រឹក្សា **គ.ទិ.ក.** ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា ១០ ..**

ក្រុមប្រឹក្សា **គ.ទិ.ក.** មានសិទ្ធិទាក់ទងនិងអញ្ជើញតំណាងក្រសួង ស្ថាប័ននានាដែលពុំមានចែងក្នុងមាត្រា៩ ខាងលើ ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងតំណាងប្រទេសនានា តាមការចាំបាច់ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍។

**មាត្រា ១១ ..**

ក្រុមប្រឹក្សា **គ.វិ.ក.** មានភារកិច្ចដូចតទៅ ÷

- អនុម័តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ **គ.វិ.ក.**
- តាមដាននិងត្រួតពិនិត្យដំណើរការការងារ **គ.វិ.ក.**
- ផ្តល់យោបល់ដល់អគ្គលេខាធិការដ្ឋានអំពីការងារចាំបាច់
- សម្របសម្រួលនិងដោះស្រាយរាល់វិវាទផ្សេងៗរបស់ **គ.វិ.ក.**
- ផ្តល់យោបល់ក្នុងការចុះបញ្ជីវិស្វករអាជីព ការលើកទឹកចិត្ត និងការដាក់វិន័យ ។

**មាត្រា ១២ ..**

ក្រុមប្រឹក្សា **គ.វិ.ក.** ត្រូវប្រជុំយ៉ាងតិចរៀងរាល់ ០១ (មួយ) ឆ្នាំម្តង។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំជាវិសាមញ្ញបាន ។

## ជំពូកទី៤

## អគ្គលេខាធិការដ្ឋាន

**មាត្រា ១៣ ..**

**គ.វិ.ក.** មានអគ្គលេខាធិការដ្ឋានមួយ ដែលមានតួនាទីជាអង្គភាពប្រតិបត្តិ និងមានភារកិច្ចដូចតទៅ ÷

- រៀបចំ និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌វិស្វករ ដែលអនុម័តដោយក្រុមប្រឹក្សា **គ.វិ.ក.**
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ដំណើរការ **គ.វិ.ក.**
- ធានានិរន្តរភាពការងារនៃអគ្គលេខាធិការដ្ឋាន **គ.វិ.ក.**
- ផ្សព្វផ្សាយអនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងនឹងវិស័យវិស្វកម្មគ្រប់ជំនាញ និងចូលរួមរៀបចំច្បាប់ និងបទដ្ឋានគតិយុត្តទាំងឡាយ តាមការអញ្ជើញរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ជួយសម្រួលក្នុងការការពារកម្មសិទ្ធិបញ្ញារបស់វិស្វករអាជីព
- ពង្រឹងសមត្ថភាពចូលរួមក្នុងការប្រកួតប្រជែងដោយយុត្តិធម៌ និងស្មើភាពគ្នារវាងវិស្វករអាជីពកម្ពុជា និងវិស្វករបរទេស
- ធ្វើសហប្រតិបត្តិការជាមួយក្រសួងអប់រំយុវជន និងកីឡា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា គ្រឹះស្ថានឧត្តមសិក្សា និងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់កម្មវិធីសិក្សា វគ្គបំប៉នជំនាញ និងការអប់រំក្រោយឧត្តមសិក្សា
- លើកស្ទួយការបណ្តុះបណ្តាលបន្តដល់វិស្វករកម្ពុជា ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈវិស្វកម្មឱ្យមានការទទួលស្គាល់ក្នុងក្របខណ្ឌអាស៊ាន និងអន្តរជាតិ តាមគោលការណ៍នៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកក្នុងអាស៊ាន
- ពិនិត្យតាមដានការប្រកបវិជ្ជាជីវៈវិស្វកម្មរបស់វិស្វករអាជីពកម្ពុជា និងវិស្វករបរទេស
- ចុះបញ្ជីកំណត់គុណវុឌ្ឍិអាជីពវិជ្ជាជីវៈវិស្វកម្មរបស់រូបវន្តបុគ្គលឱ្យទៅជាវិស្វករអាជីព និងធានានិរន្តរភាព

ROYAUME DU CAMBODGE
LE MINISTRE ... PALAIS ROYAL

ការចុះបញ្ជីវិស្វករអាជីព នៅព្រះរាជាណាចក្រកម្ពុជា

- ជ្រើសរើស និងវាយតម្លៃលើបេក្ខភាពវិស្វករអាជីពកម្ពុជា ដើម្បីឱ្យទៅជាវិស្វករអាស៊ាន
- រៀបចំគុណវុឌ្ឍិជំនាញវិជ្ជាជីវៈ និងក្រមសីលធម៌របស់វិស្វករអាជីពដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- ធ្វើកោសល្យវិច័យលើការអនុវត្តការងាររបស់វិស្វករអាជីព ក្នុងករណីមានទំនាស់ក្នុងការបំពេញវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារ **គ.វ.ក.** ក្នុងកិច្ចប្រជុំប្រចាំឆ្នាំ និងក្រុមប្រឹក្សា **គ.វ.ក.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូន ដោយក្រុមប្រឹក្សា **គ.វ.ក.** ។

**មាត្រា ១៤ ..**

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ។ អគ្គលេខាធិការមានឋានៈទាបបំផុតស្មើរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមានឋានៈទាបបំផុតស្មើអនុរដ្ឋលេខាធិការ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន **គ.វ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៥ ..**

អគ្គលេខាធិការនិងអគ្គលេខាធិការរង **គ.វ.ក.** ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត ដោយមហាសន្និបាត **គ.វ.ក.** សម្រាប់អាណត្តិ ០៥ (ប្រាំ) ឆ្នាំ។

វិស្វករដែលមានសញ្ជាតិខ្មែរអាចឈរឈ្មោះឱ្យ **គ.វ.ក.** បោះឆ្នោតជាអគ្គលេខាធិការ ឬអគ្គលេខាធិការរងបានត្រូវមានឈ្មោះក្នុងបញ្ជីវិស្វករអាជីពយ៉ាងតិច ០៥(ប្រាំ)ឆ្នាំ ហើយមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋណាមួយឡើយ ។

**មាត្រា ១៦ ..**

ករណីដែលអគ្គលេខាធិការ ឬអគ្គលេខាធិការរងណាម្នាក់ទទួលមរណភាព ឬលាឈប់ពីមុខងារក្នុងអាណត្តិរបស់ខ្លួន **គ.វ.ក.** ត្រូវជ្រើសរើសអ្នកជំនួសដើម្បីបញ្ចប់អាណត្តិ ស្របតាមបទបញ្ជាផ្ទៃក្នុង ។

**មាត្រា ១៧ ..**

**គ.វ.ក.** មាននិមិត្តសញ្ញា និងត្រាដោយឡែករបស់ខ្លួន ។

## ជំពូកទី៥

## ក្រុមប្រឹក្សាគណៈវិស្វកររាជធានី ខេត្ត

**មាត្រា ១៨ ..**

**គ.វ.ក.** អាចបង្កើតក្រុមប្រឹក្សាគណៈវិស្វកររាជធានី ខេត្តបាន ក្នុងករណីដែលមានសមាជិកជាវិស្វករចុះបញ្ជីចាប់ពី ២០ (ម្ភៃ) រូបឡើងទៅ ដែលក្នុងនោះត្រូវមានវិស្វករអាជីពយ៉ាងតិច ០៥(ប្រាំ)រូប ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគណៈវិស្វកររាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.វិ.ក.** ។

## ជំពូកទី៣
## ការប្រកបវិជ្ជាជីវៈវិស្វកម្ម

**មាត្រា ១៩ ..**

វិស្វករ ដែលអាចក្លាយទៅជាវិស្វករអាជីពបាន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

- បានចុះបញ្ជី **គ.វិ.ក.**
- គ្មានការហាមឃាត់ការប្រកបវិជ្ជាជីវៈនេះដោយតុលាការ និង
- បំពេញលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.វិ.ក.** ។

**មាត្រា ២០ ..**

វិស្វករអាជីពអាចប្រកបវិជ្ជាជីវៈវិស្វកម្មដោយខ្លួនឯងបាន ដោយត្រូវគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

វិស្វករអាចប្រកបវិជ្ជាជីវៈវិស្វកម្មបានដោយមានការទទួលខុសត្រូវរបស់វិស្វករអាជីព។

**មាត្រា ២១ ..**

វិស្វករដែលបានបំពេញគ្រប់លក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១៩ ខាងលើត្រូវទទួលបានវិញ្ញាបនបត្រវិស្វករអាជីពដែលចេញ ដោយ **គ.វិ.ក.** ។

**មាត្រា ២២ ..**

ជនបរទេសដែលមានបំណងប្រកបវិជ្ជាជីវៈវិស្វកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីនៅ **គ.វិ.ក.** និងត្រូវគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២៣ ..**

ការប្រកបវិជ្ជាជីវៈវិស្វកម្ម ត្រូវគោរពតាមក្រមសីលធម៌វិស្វករ ដែលអនុម័តដោយក្រុមប្រឹក្សា **គ.វិ.ក.** ។

**មាត្រា ២៤ ..**

វិស្វករខ្មែរនិងវិស្វករបរទេស ដែលបានចុះបញ្ជី **គ.វិ.ក.**នៅព្រះរាជាណាចក្រកម្ពុជា ត្រូវបង់ភាគទានប្រចាំឆ្នាំជូន **គ.វិ.ក.** ។

ភាគទានដែលត្រូវបង់ជូន **គ.វិ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.វិ.ក.** ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ២៥**

វិស្វករចុះបញ្ជី និងវិស្វករអាជីព អាចសុំព្យួរការប្រកបវិជ្ជាជីវៈរបស់ខ្លួនបាន តាមការកំណត់របស់ **គ.ទ.ក.** ។

## ជំពូកទី៤

## គោរមងារកិត្តិយស

**មាត្រា ២៦ ..**

**គ.ទ.ក.** អាចផ្តល់គោរមងារជាវិស្វករកិត្តិយសជូនដល់វិស្វករអាជីព ក្រោយពីបានប្រកបវិជ្ជាជីវៈវិស្វកម្ម រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ ។

**គ.ទ.ក.** អាចផ្តល់គោរមងារជាសមាជិកកិត្តិយសជូនដល់ឥស្សរជន ឬបុគ្គលទាំងឡាយណា ដែលបានឧបត្ថម្ភគាំទ្រផ្នែកថវិកា ឬ បច្ចេកទេសដល់ **គ.ទ.ក.** តាមការកំណត់របស់ក្រុមប្រឹក្សា **គ.ទ.ក.** ។

**មាត្រា ២៧ ..**

គោរមងារជាវិស្វករកិត្តិយសអាចត្រូវដកវិញបាន ប្រសិនបើវិស្វកររូបនោះបានប្រព្រឹត្តផ្ទុយនឹងវិធានបច្ចេកទេស ឬក្រមសីលធម៌វិស្វករ ទោះបីការប្រព្រឹត្តនោះ នៅក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ ។

## ជំពូកទី៥

## ក្រុមប្រឹក្សាវិន័យ

**មាត្រា ២៨ ..**

ក្រុមប្រឹក្សាវិន័យមានសមាសភាពចំនួន ០៥ (ប្រាំ) រូប ដែលត្រូវតែងតាំងឡើងដោយប្រធានក្រុមប្រឹក្សា **គ.ទ.ក.** ក្នុងចំណោមសមាជិកក្រុមប្រឹក្សា **គ.ទ.ក.** និងសមាជិកនៃអគ្គលេខាធិការដ្ឋាន **គ.ទ.ក.** ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការសម្រេចដាក់វិន័យ ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង **គ.ទ.ក.** ។

**មាត្រា ២៩ ..**

ក្រុមប្រឹក្សាវិន័យមានតួនាទីដូចតទៅ ÷

- ទទួលបណ្តឹងតវ៉ាផ្សេងៗពាក់ព័ន្ធនឹងវិស្វករដែលបានចុះបញ្ជីនៅ **គ.ទ.ក.**
- ដោះស្រាយវិវាទទាក់ទងនឹងវិជ្ជាជីវៈវិស្វករដែលបានចុះបញ្ជីនៅ **គ.ទ.ក.**
- ដាក់ទណ្ឌកម្មខាងវិន័យដល់វិស្វករណាដែលប្រព្រឹត្តផ្ទុយនឹងវិធានបច្ចេកទេស ឬក្រមសីលធម៌វិស្វករ ។

**មាត្រា ៣០ ..**

វិស្វករដែលមិនសុខចិត្តនឹងសេចក្តីសម្រេចដាក់ទណ្ឌកម្មរបស់ក្រុមប្រឹក្សាវិន័យ មានសិទ្ធិប្តឹងតវ៉ា ទៅប្រធាន ក្រុមប្រឹក្សា **គ.ទ.ក.** ។ ប្រធានក្រុមប្រឹក្សា **គ.ទ.ក.** ត្រូវចាត់តាំងសមាជិកចំនួន ០៧ (ប្រាំពីរ) រូបផ្សេងទៀត ក្រៅពីសមាសភាពក្រុមប្រឹក្សាវិន័យ ដើម្បីពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានោះ ។ សេចក្តីសម្រេចចុងក្រោយនេះ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

បែបបទ និងនីតិវិធីនៃការតវ៉ា និងរយៈពេលនៃការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង **គ.ទ.ភ.** ។

## **ជំពូកទី៦**

## **ទណ្ឌកម្មខាងវិន័យ**

**មាត្រា ៣១ ..**

ទណ្ឌកម្មខាងវិន័យរួមមាន ÷

- ការព្រមាន
- ការស្តីបន្ទោស
- ការព្យួរសិទ្ធិមួយរយៈពេលដែលពុំអាចលើសពី ០២ (ពីរ) ឆ្នាំ
- ការលុបឈ្មោះចេញពីបញ្ជី **គ.ទ.ភ.** ឬហូតគោរមងារកិត្តិយស ។

ការទទួលទណ្ឌកម្មខាងវិន័យ មិននាំឱ្យបុគ្គលនោះរួចផុតពីការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌឡើយ ។

## **ជំពូកទី៧**

## **ប្រភពធនធាន**

**មាត្រា ៣២ ..**

ប្រភពធនធានរបស់ **គ.ទ.ភ.** សម្រាប់បំពេញការងាររបស់ខ្លួនបានមកពី ÷

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ភាគទានដែលបានពីសមាជិក **គ.ទ.ភ.**
- អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ជំនួយឥតសំណងផ្សេងៗ ។

**គ.ទ.ភ.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀតពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់បម្រើការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។

## **ជំពូកទី៨**

## **អន្តរប្បញ្ញត្តិ**

**មាត្រា ៣៣ ..**

ក្នុងអាណត្តិដំបូង អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃ **គ.ទ.ភ.** ត្រូវតែងតាំងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានក្រុមប្រឹក្សា **គ.ទ.ភ.** ។

**មាត្រា ៣៤ ..**

វិស្វករទាំងឡាយដែលបាន និងកំពុង ឬមានបំណងប្រកបវិជ្ជាជីវៈវិស្វកម្ម ត្រូវមកសុំបំពេញបែបបទ និងចុះឈ្មោះក្នុងបញ្ជី **គ.វិ.ក.** ស្របតាមលក្ខខណ្ឌដែលបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា ៣៥ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣៦ ..**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

រកត.០៩០៤.៤២៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៣៧៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**



១០/១០

**ព្រះរាជក្រឹត្យ**

នស/រកត/០៤០៩/៤១៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

តែងតាំង

ឯកឧត្តម ម៉ាន់ សឿន

ជា

ឧកញ៉ា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧.០៩០៤.៤២២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩*

លេខ: ៣៩៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ០៤ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤២០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក_គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១-ឯកឧត្តម សួន សិទ្ធី
២-ឯកឧត្តម អ៊ី សំអួន

ខ_គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១-ឯកឧត្តម ម៉ឺន សំបូរ
២-លោកជំទាវ ហុង សុជាតា សួន សិទ្ធី
៣-ឯកឧត្តម ជា ទុទ្ធី
៤-លោក យុន ហេង

គ_គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១-ឯកឧត្តម អន សុផាណារ៉ា
២-លោក សេង សុចិន្តា
៣-លោក លឹម មុនី
៤-លោក ហុង លឹមហ៊ន់
៥-លោក សាមុត ធឿន
៦-ឧកញ៉ា សោម សុខរ៉ាឌី
៧-ឧកញ៉ា ឆេព រិទ្ធីវិទ្ធ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៤ ០៩០៤.៤២៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៣៨០ ច.ល
ឃើញថតចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
ឃួន ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

លោកជំទាវ ស៊ាងលីម លីហួរ

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រ/ល.០៩០៤.៤២៤

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩*

លេខ : ៤០០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤២២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

-លោក អ៊ិត ប៊ុនថុល
-លោក អ៊ិត សីម៉ា

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤០.០៩០៤.៤២៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៣៨១ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម **ឆាយ ថន**

នូវ

## គ្រឿងឥស្សរិយយស ជាតូបការ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៩០៤.៤២៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩*

លេខ: ៣៩១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤២៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :-

១-ឯកឧត្តម ហេង តៃគ្រី ៣-ឯកឧត្តម អេង ហួត
២-ឯកឧត្តម អ៊ុង គីរុន

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :-

១-លោកជំទាវ អ៊ុក ម៉ុណ្ណា ២-ឯកឧត្តម សៅ សុភខុន

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-

១-ឯកឧត្តម សុខ ផេង ៣-ឯកឧត្តម ជូ យិនស៊ីម
២-ឯកឧត្តម តែ គុយស៊ាង ៤-ឯកឧត្តម ហែម ឈិន

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សប្ញទ្ធិ ចំពោះ :-

១-ឯកឧត្តម ឆា គ្រួយ ៨-ឯកឧត្តម ឌួង សុជាតិ
២-លោកជំទាវ តាន់ ទួចឆេង ៩-លោកជំទាវ យក់ សម្បត្តិ
៣-ឯកឧត្តម ស៊ា ហួង ១០-ឯកឧត្តម ម៉ៅ តាន់អ៊ាង
៤-ឯកឧត្តម លី ឈួង ១១-ឯកឧត្តម អ៊ុង សំអាន
៥-ឯកឧត្តម ប៉ែន រិកស៊ី ១២-ឯកឧត្តម ហ៊ុយ សេដ្ឋ
៦-ឯកឧត្តម យឹម យ៉ាន់ ១៣-ឯកឧត្តម លឹម រតនៈ
៧-ឯកឧត្តម មាន ឈីវុន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤.០៩០៤.៤២៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៣៩៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤២៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **ហែម ប៊ូ** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយក ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩

៣៤៧.០៩០៤.៤២៨

លេខ : ៣៩៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការបិទស្ថានប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការយូណេស្កូ នៅទីក្រុងប៉ារីស

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

### សម្រេច

**មាត្រា ១ :** ត្រូវបានបិទ**ស្ថានប្រតិភូអចិន្ត្រៃយ៍** នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការ**យូណេស្កូ** នៅទីក្រុង**ប៉ារីស**។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ . ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ . ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ . ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក. ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក. ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក. ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៤.០០០ លានរៀល (បួនពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦១ (សេវាខាងក្រៅ) របស់ក្រសួងអប់រំ យុវជន និង កីឡា ផ្នែកឧត្ដមសិក្សា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយលើការសាងសង់អគារសាលសហសិក្សា ០១ ខ្នង (ខ្ពស់ពីដី) នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ ✓

**បានយកសេចក្ដីជំរាបជូន**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ

* * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៣០៩/៣៤៩ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើត គណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ៧៩០ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការបង្កើត គណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពលើគ្រប់ស្ថាប័ន និងគណៈកម្មាធិការនានាពាក់ព័ន្ធវិស័យ អប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគ្រប់ប្រភេទ ។

## ជំពូកទី២

## តួនាទី និង ភារកិច្ច

**មាត្រា ៣.-**

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងគណៈកម្មាធិការ ជាតិបណ្តុះបណ្តាល ជាសេនាធិការ ។

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- គ្រប់គ្រងកិច្ចការរដ្ឋបាលរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- គ្រប់គ្រងហិរញ្ញវត្ថុរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃផ្នែកក្រោមឱវាទ និងលើកសំណើកែតម្រូវ ជូនឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- ធ្វើរបាយការណ៍ជូនឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បំពេញមុខងារ និងភារកិច្ចចាំបាច់ដទៃទៀត ដែលឧត្តមក្រុមប្រឹក្សាជាតិអប់រំ ប្រគល់ជូន ។

## ជំពូកទី៣

## រចនាសម្ព័ន្ធ

**មាត្រា ៥.-**

អគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

១. ផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ

២. ផ្នែកគោលនយោបាយ

ផ្នែកនីមួយៗ មានថ្នាក់ស្មើនាយកដ្ឋាន ដែលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៦.-**

ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុមានតួនាទី និងភារកិច្ច ៖

- បូកសរុបការងារដែលពាក់ព័ន្ធនឹងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដាក់ជូនឧត្តមក្រុមប្រឹក្សាវាយតម្លៃ
- បំពេញការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- ចាត់ចែង និងរាយការណ៍ពីចំណូល ចំណាយ ជូនអគ្គលេខាធិការ
- រៀបចំ និងចាត់ចែងកិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- ធ្វើរបាយការណ៍ជូនអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បំពេញការងារទូទៅ ដែលអគ្គលេខាធិការប្រគល់ឱ្យ
- ធ្វើទំនាក់ទំនង និងសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ដើម្បីធានាប្រសិទ្ធភាពការងារ របស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- ផ្សព្វផ្សាយគោលនយោបាយ និងលទ្ធផលការងាររបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ជូនសាធារណជន ។

**មាត្រា ៧.-**

ផ្នែកគោលនយោបាយ មានតួនាទី និងភារកិច្ច ៖

- សម្របសម្រួលសំណើគោលនយោបាយអប់រំ និងយុទ្ធសាស្ត្ររយៈពេលវែងសំដៅឆ្លើយតបទៅនឹងសំណូមពរអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេសជាតិ
- រៀបចំផែនការការងាររបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- ចូលរួមប្រជុំក្នុងកិច្ចប្រជុំពាក់ព័ន្ធនឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលរៀបចំដោយក្រសួង ស្ថាប័ន នានា ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលជារដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និងកីឡា និងអមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

អគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ៩.-**

មន្ត្រីអគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ ជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ ។ ក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋាន មានសិទ្ធិជ្រើសរើសបុគ្គលិក ឬ អ្នកជំនាញជាប់កិច្ចសន្យា ដើម្បីជួយបំពេញការងាររបស់ខ្លួន។

តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ។

**មាត្រា ១០.-**

បែបបទ និងនីតិវិធីអនុវត្តការងារក្នុងអគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន ។

## ជំពូកទី៤

## រូបសញ្ញា និង ត្រា

**មាត្រា ១១.-**

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានសញ្ញាសម្គាល់ និងត្រា សម្រាប់ដំណើរការការងាររបស់ខ្លួន។

អគ្គលេខាធិការដ្ឋានប្រើប្រាស់ត្រា របស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥

## ថវិកា

**មាត្រា ១២.-**

អគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំប្រើប្រាស់ថវិកា ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា និងដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន១៧រូប ដែលមានស្នាដៃល្អក្នុងការជួយកសាងសមិទ្ធផលនានា នៅក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

| | |
|---|---|
| **១-លោក ប្រាក់ ផាវ៉ា** | មន្ត្រីនាយកដ្ឋានវាយតំលៃ និងការលើកទឹកចិត្ត គណៈកម្មាធិការវិនិយោគកម្ពុជា |
